ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៨២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីសរុបទំហំ ៤,៦៦ ហិកតា នៅស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ចេញពីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងមួយចំណែករក្សាទុកជាដីសាធារណៈរបស់រដ្ឋ ព្រមទាំងផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែមេសា ឆ្នាំ ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ ២៨១/១៧ អបខ ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៧ របស់រដ្ឋបាលខេត្តកំពង់ស្ពឺ
- បានឃើញលិខិតលេខ ៣៨៦៨ កសក ចុះថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

# សម្រេច

**មាត្រា ១** : ត្រូវបានកាត់ផ្ទៃដីទំហំ ៤,៦៦ ហិកតា ចេញពីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ដាំដុះជាក់ស្តែង ទំហំ ៤,៥៩ ហិកតា និងផ្ទៃដីទំហំ ០,០៧ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ ស្ថិតនៅ**ភូមិអូរសំបួរ ឃុំក្រាំងអំពិល ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ** តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ(១) និង(២) នៃអនុក្រឹត្យនេះ ។

**មាត្រា ២** : ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ១១ គ្រួសារ នៅ **ភូមិអូរសំបួរ ឃុំក្រាំងអំពិល ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ** ។

**មាត្រា ៣** : ផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនចំនួន ១៨ ក្បាលដី ជូនប្រជាពលរដ្ឋ ១១ គ្រួសារ ស្ថិតនៅ **ភូមិអូរសំបួរ ឃុំក្រាំងអំពិល ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ** ។

**មាត្រា ៤** : ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែងគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៥** : បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែឧសភា ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក. ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ២០១៧ ស្តីពីការកាត់ឆ្វៀលផ្ទៃដីសរុបទំហំ ៤,៦៦ហិកតា ចេញពីផែនទីគម្របព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ១១គ្រួសារ នូវផ្ទៃដីទំហំ ៤,៥៩ហិកតា ដែលបានកាន់កាប់ ប្រើប្រាស់ និងជាំផ្ទះជាក់ស្តែង និងដីទំហំ ០,០៧ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ ស្ថិតនៅភូមិអូរសំបួរ ឃុំក្រាំងអំពិល ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ




កំពង់ស្ពឺ,ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ២០១៧

ប្រធានក្រុមវាស់វែង

សំ_ណាង

លេខ ២៣៤ ជនសស.កស្ព

បានឃើញ និងពិនិត្យត្រឹមត្រូវ

កំពង់ស្ពឺ,ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ២០១៧

ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តកំពង់ស្ពឺ

ឆាយ ម៉ារិទ្ធ

លេខ ៤៨១/១៧ ខសប២

បានឃើញ និងឯកភាព

កំពង់ស្ពឺ,ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ២០១៧

អភិបាលនៃគណៈអភិបាលខេត្ត និងជា

ប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋ ខេត្តកំពង់ស្ពឺ

ឃ្មី សំណាង

ឧបសម្ព័ន្ធ....... ចំណុចនិយាមការព្រំដី ដែលស្នើសុំកាត់ចេញពីផែនទីគម្របព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ១១គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង ស្ថិតនៅភូមិអូរសំបួរ ឃុំត្រាំងអំពិល ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ

តារាងចំណុចនិយាមកា

Projection UTM, Zone 48N, Datum WGS 84

(I)

| ID | X | Y | ID | X | Y |
|---|---|---|---|---|---|
| 1 | 445036 | 1257201 | 32 | 445085 | 1257016 |
| 2 | 445025 | 1257183 | 33 | 445087 | 1257070 |
| 3 | 445010 | 1257136 | 34 | 445090 | 1257085 |
| 4 | 445000 | 1257088 | 35 | 445092 | 1257100 |
| 5 | 444998 | 1256980 | 36 | 445096 | 1257099 |
| 6 | 444936 | 1256920 | 37 | 445112 | 1257096 |
| 7 | 444929 | 1256924 | 38 | 445135 | 1257097 |
| 8 | 444927 | 1256913 | 39 | 445135 | 1257099 |
| 9 | 444927 | 1256912 | 40 | 445140 | 1257099 |
| 10 | 444979 | 1256898 | 41 | 445146 | 1257103 |
| 11 | 444989 | 1256896 | 42 | 445151 | 1257110 |
| 12 | 444989 | 1256896 | 43 | 445151 | 1257132 |
| 13 | 445011 | 1256890 | 44 | 445147 | 1257135 |
| 14 | 445016 | 1256896 | 45 | 445132 | 1257139 |
| 15 | 445087 | 1256883 | 46 | 445112 | 1257141 |
| 16 | 445125 | 1256872 | 47 | 445092 | 1257144 |
| 17 | 445119 | 1256842 | 48 | 445094 | 1257169 |
| 18 | 445120 | 1256842 | 49 | 445117 | 1257168 |
| 19 | 445120 | 1256842 | 50 | 445119 | 1257188 |
| 20 | 445121 | 1256842 | 51 | 445119 | 1257191 |
| 21 | 445168 | 1256835 | | (II) | |
| 22 | 445168 | 1256867 | 52 | 445264 | 1258319 |
| 23 | 445197 | 1256865 | 53 | 445239 | 1258324 |
| 24 | 445200 | 1256886 | 54 | 445196 | 1258331 |
| 25 | 445174 | 1256891 | 55 | 445189 | 1258288 |
| 26 | 445125 | 1256898 | 56 | 445156 | 1258175 |
| 27 | 445076 | 1256909 | 57 | 445166 | 1258165 |
| 28 | 445075 | 1256925 | 58 | 445176 | 1258164 |
| 29 | 445074 | 1256942 | 59 | 445200 | 1258164 |
| 30 | 445072 | 1256976 | 60 | 445225 | 1258161 |
| 31 | 445071 | 1257016 | 61 | 445259 | 1258272 |

កំពង់ស្ពឺ,ថ្ងៃទី..២៩... ខែ..៥..... ឆ្នាំ២០១៧

ប្រធានក្រុមវាស់វែង

សំណាង

លេខ..២៣៦.....ជនសស.កស្ក

បានឃើញ និងពិនិត្យត្រឹមត្រូវ

កំពង់ស្ពឺ,ថ្ងៃទី..២៩... ខែ....... ឆ្នាំ២០១៧

ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ស្ពឺ

ឆាយ ម៉ាឡែ

លេខ៤៩១/១៧...ឥបខ.

បានឃើញ និងឯកភាព

កំពង់ស្ពឺ,ថ្ងៃទី...២៥... ខែ...៥... ឆ្នាំ២០១៧

អភិបាល នៃគណៈអភិបាលខេត្ត និងជា

ប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋ ខេត្តកំពង់ស្ពឺ

ធ៊ុំ សំណាង